ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ពិសេស ឧស................

# ញត្តិគាំទ្រ

យើងខ្ញុំទាំងអស់គ្នា ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម សូមប្រកាសគាំទ្រយ៉ាងពេញទំហឹងចំពោះរាល់ដំណោះស្រាយ និងចំណាត់ការរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងស្មារតីទទួលខុសត្រូវដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចំពោះបញ្ហាផែនទីព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលកន្លងមក មានជនអគតិមួយចំនួន ដើម្បីចង់កេងយកចំណេញក្នុងផ្លូវនយោបាយ ក្នុងការស្វែងរកប្រជាប្រិយភាព បានឃោសនាប្រឆាំងដោយផ្កាប់មុខ និងបាននិយាយបំផុសបំផុលមូលបង្កាច់បំផ្លើសពីការពិតទាំងស្រុង ពីសទៅជាខ្មៅ ដោយចោទប្រកាន់ថា រាជរដ្ឋាភិបាលប្រើប្រាស់ផែនទីក្លែងក្លាយ ធ្វើឱ្យបាត់បង់ទឹកដី។ល។ រហូតហ៊ានក្លែងឯកសារសន្ធិសញ្ញាកម្ពុជា-វៀតណាម ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៩ថែមទៀត សំដៅបំភ័ន្តមតិសាធារណៈជាតិ និងអន្តរជាតិ បញ្ឆេះកំហឹងប្រជាជន បំផុសគំនិតជាតិនិយមជ្រុល បង្កឲ្យមានភាពវឹកវរចលាចលក្នុងសង្គម និងញុះញង់ឱ្យមានការបែកបាក់រវាងប្រជាជាតិខ្លួនឯងផង និងជាមួយប្រទេសជាមិត្តជិតខាងផង។ ប៉ុន្តែ ទីបំផុតសច្ចៈធម៌បានបង្ហាញយ៉ាងប្រត្យក្ស ក្រោមចំណាត់ការដ៏ឈ្លាសវៃ ប្រកបដោយប្រសិទ្ធភាពរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា តាមរយៈការរៀបចំឱ្យមានការផ្ទៀងផ្ទាត់ផែនទីផ្លូវការជាចំហចំនួន ០២លើក ជាមួយផែនទីដែលទទួលបានពីអង្គការសហប្រជាជាតិ និងពីសាធារណរដ្ឋបារាំង ដែលជាក់ស្តែងឃើញថា មានលក្ខណៈដូចគ្នាបេះបិទជាមួយផែនទីដែលរាជរដ្ឋាភិបាលបាន និងកំពុងប្រើប្រាស់សព្វថ្ងៃ ហើយអំពីបញ្ហាព្រំដែនទៀតសោត ក៏បានបង្ហាញយ៉ាងច្បាស់នូវភាពត្រឹមត្រូវ តម្លាភាព និងការធ្វើសកម្មភាពប្រកបដោយការទទួលខុសត្រូវ រវាងគណៈកម្មការព្រំដែនកម្ពុជា-វៀតណាម ដោយឈរលើស្មារតីគោរពអធិបតេយ្យភាព និងបូរណភាពដែនដីគ្នាទៅវិញទៅមក លើមូលដ្ឋានអនុវត្តត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ ច្បាប់ សន្ធិសញ្ញា និងនីតិវិធីជាធរមាន ដែលប្រការអស់ទាំងនេះ ត្រូវបានគូសបញ្ជាក់យ៉ាងច្បាស់លាស់នៅក្នុងសេចក្តីថ្លែងការណ៍ប្រកបដោយអត្ថន័យដ៏ជ្រាលជ្រៅជាប្រវត្តិសាស្ត្រ របស់

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីផ្តល់ការបំភ្លឺជូនដល់ជនរួមជាតិកម្ពុជា ស្តីពីផែនទីព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋសង្គមនិយមវៀតណាម។

លទ្ធផលដ៏គ្រប់គ្រាន់ខាងលើនេះ គឺជាការឆ្លុះបញ្ចាំងអំពីសច្ចៈភាព និងភាពត្រឹមត្រូវ របស់រាជរដ្ឋាភិបាល ហើយបានធ្វើឱ្យប្រជាជនមានការជ្រះស្រឡះលើបញ្ហាព្រំដែន ចំណែកឯក្រុម ជនអគតិដែលបានធ្វើការប្រឆាំងផ្កាប់មុខ ទាំងងងើល ត្រូវបរាជ័យយ៉ាងអាម៉ាស់បំផុតក្នុងឧបាយកល របស់ខ្លួន។

ជាថ្មីម្តងទៀត យើងខ្ញុំទាំងអស់គ្នា ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួង ឧស្សាហកម្ម និងសិប្បកម្ម សូមប្រកាសគាំទ្រយ៉ាងឱឡារិកបំផុត ចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែល មាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខដ៏ខ្ពង់ខ្ពស់ ដែលតែងតែបូជា កម្លាំងកាយ កម្លាំងចិត្ត និងប្រកាន់ខ្ជាប់នូវឧត្តមគតិស្នេហាជាតិដ៏ឧត្តុង្គឧត្តម ក្នុងបុព្វហេតុ ការពារ អធិបតេយ្យ និងបូរណភាពទឹកដីរបស់ជាតិមាតុភូមិ ក្នុងកិច្ចខិតខំប្រឹងប្រែងប្រកបដោយការទទួល ខុសត្រូវខ្ពស់ បន្តចរចាដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសវៀតណាម ដោយផ្អែកលើសន្ធិសញ្ញា បំពេញបន្ថែមឆ្នាំ២០០៥ និងផែនទីព្រំដែនអមសន្ធិសញ្ញានេះ ដែលជាផែនទីផ្លូវការតែមួយគត់ និង មានតម្លៃគតិយុត្ត ស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់ជាតិនៃព្រះរាជាណាចក្រកម្ពុជា និងស្របតាមច្បាប់ អន្តរជាតិ សំដៅកសាងខ្សែបន្ទាត់ព្រំដែនកម្ពុជាមួយ មានភាពច្បាស់លាស់ ត្រឹមត្រូវ ប្រកបដោយ សន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍ ឆ្លើយតបទៅនឹងបំណង ប្រាថ្នាដ៏ពិសិដ្ឋ និង ឧត្តមប្រយោជន៍របស់ប្រជាជនកម្ពុជា។

យើងខ្ញុំទាំងអស់គ្នា សូមធ្វើការថ្កោលទោសយ៉ាងដាច់អហង្ការចំពោះទង្វើរបស់ជនអគតិ មួយចំនួនដែលតែងតែបានធ្វើការប្រឌិត និងចោទប្រកាន់មួលបង្កាច់ទាំងងងឹតងងល់ ប្រកបដោយ ឧបាយកលទុច្ចរិតនាពេលកន្លងមក ដើម្បីបម្រើនយោបាយប្រជាភិថុតរបស់ក្រុមខ្លួន មកលើកិច្ច ខំប្រឹងប្រែងដ៏ស្មោះសរ និងដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលក្នុងការងារព្រំដែននេះ និងសូមអំពាវនាវ ម្តងហើយម្តងទៀតដល់អាជ្ញាធរមានសមត្ថកិច្ចចាត់វិធានការផ្លូវច្បាប់ឲ្យបានម៉ឺងម៉ាត់បំផុត ដើម្បីពង្រឹង នីតិរដ្ឋ ក្នុងគោលបំណងថែរក្សាឆ្លុងសាមគ្គីភាព ឯកភាពជាតិ និងធានាបានសុខសន្តិភាព ស្ថិរភាព សង្គម និងសណ្តាប់ធ្នាប់សាធារណៈ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០១៥